Office of

Governor Tim Walz
Lt. Governor Peggy Flanagan

COVID-19 Response and Preparation

**អភិបាលខេត្ត ធិម វ៉ល** **Governor Tim Walz (khmer)**

“ខ្ញុំចង់បញ្ជាក់អំពីសារៈសំខាន់មួយ ជូនចំពោះពលរដ្ឋមិនីសូតាទាំងអស់ថា បងប្អូនដែលមានដើមកំណើតមកពីអាស៊ីប៉ាស៊ីហ្វិក (API) មានបទពិសោធន៍ពី ការប្រកាន់រើសអើង សំដីមើលងាយស្អប់ខ្ពើម និងចរឹតមើលងាយ យ៉ាងខ្លាំង ដោយសារការរាតត្បាតនៃជម្ងឺសព្វថ្ងៃនេះ ដែលយើងទាំងអស់គ្នាកំពុងជួបប្រទះពេលនេះ។”

- “ខ្ញុំសូមជំរាបអោយបានច្បាស់ថា សហគមន៍អាស៊ីប៉ាស៊ីហ្វិករដ្ឋមិនីសូតា(API)ត្រូវបានរាប់បញ្ចូលជាពលរដ្ឋមិនីសូតាតែមួយ គ្រប់អ្វីៗដែលយើងធ្វើ។ ”
- “យើងជាពលរដ្ឋមិនីសូតាទាំងអស់ នឹងមិនអនុញ្ញាតិអោយមានការប្រកាន់ ពូជសាស្រ្ត ឬការមើលងាយចំពោះបងប្អូនអាស៊ីនៅពេលនេះ ឬពេលណាទាំងអស់។ ការភ័យខ្លាចដែលយើងមានទាក់ទង ជាមួយការរាតត្បាតជម្ងឺទូរទាំងពិភពលោក មិនត្រូវទទួលយកមកប្រើប្រឆាំងចំពោះក្រុមមនុស្សជាតិណាមួយ ហើយនិងមិនត្រូវប្រើប្រឆាំងជាមួយបុគ្គលតាមរបៀបផ្សេងៗឡើយ។”
- “វ៉ាយរុសមិនចេះរើសអើងទេ ហើយយើងក៏មិនត្រូវធ្វើការរើសអើងដែរ។”
- “បើពលរដ្ឋមិនីសូតាយើងក្លាយជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មស្អប់ខ្ពើម ពីព្រោះការភ័យខ្លាចជុំវិញ COVID-19 គេត្រូវទាក់ទងក្រសួងសមត្ថកិច្ច។”
- “បើនរណាមួយមានជួបប្រទៈពីការប្រកាន់នេះនៅកន្លែងធ្វើការ ផ្ទះរដ្ឋ ឬកន្លែងសាធារណៈដោយសារ COVID-19 គេត្រូវទាក់ទងក្រសួងសិទ្ធិមនុស្សរដ្ឋមិនីសូតា។”
- “បុគ្គលិករបស់ខ្ញុំ ជាមួយក្រសួងសុវត្ថិភាពសាធារណៈ ក្រសួងសិទ្ធិមនុស្ស និងការិយាល័យអគ្គរដ្ឋអាជ្ញាកំពុងបានបន្តសហការជាមួយអ្នកដឹកនាំសហគមន៍អាស៊ីប៉ាស៊ីហ្វិក និងសមាជិកសភានិតិបញ្ញាតិ ដើម្បីទទួលយកនូវការបារម្ភទាំងឡាយ ហើយរកវិធីសាស្រ្តសំរាប់ដោះស្រាយការបារម្ភទាំងនេះ។”

សូមទាក់ទងក្រសួងសិទ្ធិមនុស្សរដ្ឋមិនីសូតាលេខ: 651-539-1133 ឬ info.MDHR@state.mn.us